CHOKCHEY FINANCE PLC.

ជោគជ័យ ហ្វាយនែន ភីអិលស៊ី

ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ




# របាយការណ៍ប្រចាំឆ្នាំ ២០១៧

# មាតិកា


១. ចក្ខុវិស័យ........................................................................................០១
២. បេសកកម្ម ..........................................................................................០១
៣. វប្បធម៌ចារឹក .........................................................................................០១
៤. តារាងលទ្ធផលសង្ខេប..............................................................................០២
៥. សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជាឆ្នាំ ២០១៧......................០៣
៦. សាររបស់ប្រធានក្រុមប្រឹក្សាភិបាល ....................................................០៤
៧. សាររបស់អគ្គនាយក...............................................................................០៦
៨. ប្រវត្តិសង្ខេបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី..........០៧
៩. រចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ................................................................០៨
១០. ភាគទុនិក.............................................................................................០៩
១១. ក្រុមប្រឹក្សាភិបាល .................................................................................១១
១២. គណៈគ្រប់គ្រង......................................................................................១២
១៣. ផលិតផលឥណទាន..................................................................................១៦
១៤. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ...................................................១៩
១៥. របាយការណ៍របស់សវនករឯករាជ្យ.........................................................២៣
១៦. ទំនាក់ទំនងព័ត៌មាន ..............................................................................៣០



## ចក្ខុវិស័យ

យើងប្ដេជ្ញាប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោក និងមានវិសាលភាពលុបលើវិស័យធនាគារ ទាំងលើទំហំផលចំណេញ និងការទទួលស្គាល់នូវកិត្យានុភាពរបស់យើង (ភាពជឿជាក់ ការផ្ដល់ភាពងាយស្រួល និងភាពលឿនរហ័សនៃការផ្ដល់សេវាកម្ម) និងការបំពេញចិត្តទៅដល់បុគ្គលិកគ្រប់ជាន់ថ្នាក់។

## បេសកកម្ម

ជាក្រុមហ៊ុនដែលទទួលបាននូវភក្ដីភាពយូរអង្វែងពីសំណាក់អតិថិជនគោលដៅដែលស្ថិតក្នុងកម្រិតជីវភាពទាប និងមធ្យម តាមរយៈការផ្ដល់កម្ចី និងសេវាកម្មហិរញ្ញវត្ថុដើម្បីជួយលើកកម្ពស់ការរីកចម្រើននៃអាជីវកម្មប្រកបដោយនិរន្តរភាព ព្រមទាំងរួមចំណែកបង្កើតនូវ "វប្បធម៌នៃទម្លាប់ជោគជ័យ" សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

## វប្បធម៌ចារឹក

ជាស្ថាប័នប្រកបដោយសក្ដានុពល យើងមានចក្ខុវិស័យរួមជាសកល ដើម្បីប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោក ដោយឈរលើមូលដ្ឋានទម្លាប់នៃការបង្កើតភាពជោគជ័យ និងការអភិវឌ្ឍខ្លួនសម្រាប់ការផ្លាស់ប្ដូរជាវិជ្ជមាន។ យើងទាំងអស់ប្រឹងប្រែងដើម្បីការរីកចម្រើនរួមគ្នា និងផ្ដល់ភាពរីករាយសម្រាប់ជីវិតឯកជនរបស់យើង។ យើងទាំងអស់គ្នាគឺ គ្រួសារជោគជ័យ ហ្វាយនែន។

# តារាងលទ្ធផលសង្ខេប

| ប្រតិបត្តិការសំខាន់ៗ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនខេត្ត-ក្រុងប្រតិបត្តិការ | ២ | ៧ |
| ចំនួនស្រុកប្រតិបត្តិការ | ១៨ | ២៨ |
| ចំនួនឃុំប្រតិបត្តិការ | ៦៤ | ១០៤ |
| ចំនួនភូមិប្រតិបត្តិការ | ៩៧ | ២១៣ |
| ចំនួនការិយាល័យប្រតិបត្តិការ | ១ | ១ |
| ចំនួនបុគ្គលិកសរុប | ២៤ | ៧៧ |
| ចំនួនអតិថិជនឥណទានសរុប | ២៩៦ | ៣៥០ |
| ផលិតភាពបុគ្គលិកមន្ត្រីឥណទាន (គិតជាដុល្លារ) | ១៥២,៩២៥ | ១០៩,៤៨២ |
| ផលិតភាពបុគ្គលិកសរុប (គិតជាដុល្លារ) | ៥៧,៣៤៧ | ៣២,២៨៣ |
| ទំហំឥណទានមធ្យម (គិតជាដុល្លារ) | ៤,៦៥០ | ៧,១៩៥ |
| ឥណទានមានហានិភ័យលើស៣០ថ្ងៃ | ២.៧% | ៥.៣៤% |
| សមតុល្យឥណទានសរុប (គិតជាដុល្លារ) | ១,៣៧៦,៣២៩ | ២,៥១៨,០៨០ |
| ទ្រព្យសកម្មសរុប (គិតជាដុល្លារ) | ១,៥៦៤,២០១ | ៣,៦៤២,០២០ |

# សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជាឆ្នាំ ២០១៧

| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦e | ២០១៧f |
|---|---|---|---|---|---|---|
| **១. ផលិតផលសរុបក្នុងស្រុក (GDP)** | | | | | | |
| បម្រែបម្រួលផលិតផលសរុបក្នុងស្រុក (គិតជាភាគរយ) | ៧,៣ | ៧,៤ | ៧,១ | ៧ | ៧ | ៧ |
| ចំណូលក្នុងម្នាក់ (គិតជាដុល្លារអាមេរិក) | ៩៧៣ | ១.០៤៣ | ១.១៣៨ | ១.២១៥ | ១.៣០០ | ១.៤២២ |
| **២. អតិផរណា** | | | | | | |
| អតិផរណា (មធ្យមប្រចាំឆ្នាំ) | ២,៩ | ៣ | ៣,៩ | ១,២ | ២,៨ | ៣,៧ |
| (ចុងឆ្នាំ) | ២,៥ | ៤,៦ | ១,១ | ២,៦ | - | - |
| **៣. ថវិការបស់រដ្ឋាភិបាល (គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក)** | | | | | | |
| ចំណូល | ១៦,៩ | ១៨,៤ | ១៧,៥ | ១៨,៩ | ១៧,៩ | ១៨,២ |
| ចំណាយ | ២០,៧ | ២០,៥ | ២១,៥៥ | ២០,៩ | ២២,៨ | ២៣,១ |
| **៤. រូបិយវត្ថុ និងឥណទាន (បម្រែបម្រួលជាភាគរយក្នុង១២ខែ)** | | | | | | |
| រូបិយវត្ថុទូទៅ (M2) | ២០,៩ | ១៤,៦ | ២៩,៩ | ១៤,៧ | ២០,៨ | - |
| ប្រាក់បញ្ញើសរុបនៅក្នុងប្រព័ន្ធធនាគារ | ២៤,៩ | ១៣,៨ | ៣០,១ | ១៦,៤ | ២០ | - |
| ឥណទានសរុបនៅក្នុងប្រព័ន្ធធនាគារ | ៣៥,១ | ២៥,២ | ១៦,២ | ២៥,៧ | ១៨ | - |
| ឥណទានធៀបនឹងប្រាក់បញ្ញើ (គិតជាភាគរយ) | ៨៦,៨ | ៩៨ | ៩៤ | ១០២,៦ | ១០១,៧ | - |
| ឥណទានវិស័យឯកជន | ២៨,០ | ២៦,៧ | ៣១,៣ | ២៧,១ | ២១,៦ | - |
| ប្រាក់បញ្ញើធៀបនឹងផលិតផលសរុបក្នុងស្រុក | ៤៧,៣ | ៤៩ | ៥៣ | ៦១,៩ | ៦៧,៨ | - |
| ឥណទានធៀបនិងផលិតផលសរុបក្នុងស្រុក | ៤១ | ៤៩,៨ | ៥០ | ៦៣,៥ | ៦៩ | - |
| **៥. ជញ្ជីងទូទាត់ (គិតជាលានដុល្លារអាមេរិក)** | | | | | | |
| ការនាំចេញ | ៦.០១៥,៧ | ៦.៥៣០ | ៧.៤០៨e | ៨.២០៨,៨ | ៩.០១៧,៧ | ៩.៩៣៦,៧ |
| ការនាំចូល | -៨.៤២៦ | -៩.៧៤៤ | -១០.៩៩១e | -១០.៥៤២ | -១១.៤៤៩,៦ | -១២.៥៥៩,៣ |
| ជញ្ជីងពាណិជ្ជកម្ម | -២.៩៦៧ | -៣.២១៤ | -៣.៥៨៣e | -២.៣៣៣,២ | -២.៤៣១,៩ | -២.៦២២,៦ |
| គណនីចរន្ត (មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ) | -១.៨៣៥ | -២.១៧១ | -២.៣៥៦e | -១.៩០៨,៤ | -២.០៣៩,១ | -២.២១៩,១ |
| ផលិតផលសរុបក្នុងស្រុកជាមធ្យម (គិតជាពាន់លានដុល្លារអាមេរិក) | ១៤,១ | ១៥,៣៥ | ១៦,៩១ | ១៨,០៨ | ២០,០៩ | ២២,២១ |
| អត្រាប្តូរប្រាក់ (រៀលក្នុងមួយដុល្លារនៅចុងគ្រា) | ៤.០៣៣ | ៤.០២៧ | ៤.០៣៨ | ៤.០៦០ | ៤.០៥០ | ៤.០៥០ |

**ប្រភព៖ សមាគមធនាគារនៅកម្ពុជា ធនាគារជាតិនៃកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។**
e: **ប៉ាន់ប្រមាណ និង** f: **ព្យាករណ៍។**



# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

នៅក្នុងឆ្នាំ ២០១៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី បានធ្វើការបោះជំហានថ្មីមួយដ៏គួរឲ្យកត់សម្គាល់គឺ ការផ្លាស់ប្តូរភាគទុនិក ដែលក្នុងនោះ ភាគហ៊ុន ចំនួន ៥១% បានផ្ទេរទៅឲ្យក្រុមហ៊ុន Hanshin Engineering and Construction Co., Ltd ដែលជាក្រុមហ៊ុន សំណង់ដ៏ធំមួយនៅប្រទេសកូរ៉េខាងត្បូង និងភាគហ៊ុនចំនួន ៤៩% បានផ្ទេរទៅឲ្យក្រុមហ៊ុន Plus International Co., Ltd.។ ជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោកដែលពោរពេញសក្តានុពល និងកិត្យានុភាព ក្រុមហ៊ុន Hanshin Engineering and Construction Co., Ltd. ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៦៧ ហើយបាននឹង កំពុងពង្រីកប្រតិបត្តិការ របស់ខ្លួនទាំងក្នុងប្រទេស និងក្នុងតំបន់ ដូចជាប្រទេស អារ៉ាប៊ីសាអូឌីត ប្រទេសគុយវ៉ែត ប្រទេសម៉ុងហ្គោល ប្រទេសឡាវ ប្រទេសកម្ពុជា ប្រទេសភូមា ប្រទេសវៀតណាម និងប្រទេសហ្វីលីពីន។ល។

ដោយឡែកនៅប្រទេសកម្ពុជា ក្រុមហ៊ុន Hanshin បានរួមចំណែកក្នុងការកសាងរចនាសម្ព័ន្ធផ្លូវថ្នល់ តួយ៉ាងផ្លូវជាតិលេខ២១ ផ្លូវជាតិលេខ ៥ និងផ្លូវនៅខេត្តបាត់ដំបង ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា។

លើសពីនេះទៀតគិតត្រឹមឆ្នាំ ២០១៥ ក្រុមហ៊ុន Hanshin បានផ្តល់អាហារូបករណ៍ដល់និស្សិតវៀតណាម ចំនួនជាង១ម៉ឺន ២ពាន់នាក់ ដើម្បីបន្តការសិក្សានៅប្រទេសកូរ៉េខាងត្បូង។ ក្រុមហ៊ុន Plus International Co., Ltd. ជាក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍ ដែលផ្តោតលើគម្រោងអភិវឌ្ឍអចលនទ្រព្យ និងការកសាងសំណង់អគារធំៗ អគារស្នាក់នៅ និងអគារការិយាល័យ ។ល។ ក្រៅពីនេះ ក្រុមហ៊ុន Plus ក៏បានបង្កើតសាលាវិជ្ជាជីវៈឯកទេសកែសម្ផស្ស និងហាងកែសម្ផស្ស ផាត់មុខ តាមបែបកូរ៉េ ដែលមានមូលដ្ឋាននៅទីក្រុងហាណូយ ប្រទេសវៀតណាម ហើយក៏មានគម្រោងបោះជំហាន ចូលមកក្នុងប្រទេសកម្ពុជានាពេលអនាគតផងដែរ។

ក្រោមការគ្រប់គ្រង របស់ភាគទុនិកថ្មី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី បានចាប់ផ្តើមចាប់យកឱកាសដើម្បីរីកលូតលាស់ និងឈរជើងយ៉ាងរឹងមាំនៅក្នុងឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ ព្រមទាំងគម្រោងផ្លាស់ប្តូរទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើរ ឬធនាគារពាណិជ្ជនាពេលអនាគត។

ឆ្នាំ ២០១៧ សេដ្ឋកិច្ចកម្ពុជាបានបង្ហាញពីកំណើនដោយស្ថេរភាពមួយក្នុងអត្រាកំណើនប្រមាណ ៧% ។ កំណើនសេដ្ឋកិច្ចនេះទទួលបានពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ ដូចជាវិស័យសំណង់ និងអចលនទ្រព្យ ព្រមទាំងការចំណាយផ្សេងៗរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ វិស័យទេសចរណ៍ក៏បានរួមចំណែកដ៏ធំផងដែរសម្រាប់កំណើនថវិការជាតិ។

នៅដំណាច់ឆ្នាំ ២០១៧ នេះដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួនសរុប ៧៦ ដែលមានទ្រព្យសកម្មសរុប ចំនួន ២០,៣១០.០២ ប៊ីលានរៀលស្មើនឹង ២៥% នៃផលិតផលក្នុងស្រុកសរុប ព្រមទាំងមានកំណើនផលធៀបឆ្នាំលើឆ្នាំស្មើនឹង ៣០.៥% ហើយការផ្តល់ឥណទានកើនឡើងដល់ ១៧,២៣៦.៤៤ ប៊ីលានរៀល។ កំណើននៃទ្រព្យសកម្ម និងឥណទាន បានឆ្លុះបញ្ចាំងពីកិច្ចគាំទ្រនៃវិស័យមីក្រូហិរញ្ញវត្ថុដល់សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ឥណទានដែលមានហានិភ័យនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានចំនួន ២.១% ក្នុងឆ្នាំ២០១៧ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តគោរពតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដោយបានរក្សានូវអនុបាតសាធនភាព និងអនុបាតសន្ទនីយភាពស្របតាមការកំណត់ដោយបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ការកំណត់ពិដានអត្រាការប្រាក់របស់ធនាគារជាតិនៃកម្ពុជាក្នុងកម្រិត ១៨% ក្នុងមួយឆ្នាំ បានជម្រុញឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បង្កើនការយកចិត្តទុកដាក់ និងពង្រឹងប្រសិទ្ធភាពលើប្រតិបត្តិការឥណទាន។ បទប្បញ្ញត្តិនេះ នឹងអាចជួយឲ្យមានការធ្លាក់ចុះជាបន្តបន្ទាប់នៃចំណាយប្រតិបត្តិការ និងអនុបាតឥណទានមិនដំណើរការ។ ជារួមទោះបីមានបញ្ហាប្រឈមថ្មីៗមួយចំនួនក៏ដោយ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជានឹងនៅតែបន្តរីកចម្រើន និងទទួលបានជំនឿទុកចិត្តពីសំណាក់សាធារណៈជនជាដរាប។

# ទស្សនវិស័យ និងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០១៨

តាមរយៈអត្រាកំណើនក្នុងកម្រិតថេរ ៧% នៃសេដ្ឋកិច្ចកម្ពុជា គេសង្កេតឃើញថាមានកត្តាចម្បង ដូចជាការចំណាយរបស់រាជរដ្ឋាភិបាល និងការនាំចេញវាយណភ័ណ្ឌ ដោយមានការចូលរួមយ៉ាងសកម្មពីវិស័យទេសចរណ៍ និងកសិកម្ម។ ដូច្នេះជារួមការរំពឹងទុកប្រកបដោយទស្សនវិជ្ជមាន នឹងនៅតែមានបន្តទៅទៀត ស្របពេលនិន្នាការបង្កើនការធ្វើពាណិជ្ជកម្ម និងការវិនិយោគពីសមាហរណកម្មថ្នាក់តំបន់។ ដោយឡែកហានិភ័យមួយចំនួនដែល អង្កេតឃើញរួមមាន ការធ្លាក់ចុះអត្រាប្តូរប្រាក់ដុល្លារអាមេរិក ភាពយឺតយ៉ាវនៃកំណើនសេដ្ឋកិច្ចពិភពលោក និងភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបោះឆ្នោតនៅកម្ពុជានាពេលខាងមុខ។

ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសំណង់លំដាប់អន្តរជាតិ ជោគជ័យ ហ្វាយនែន ទទួលបានការគាំទ្រយ៉ាងពេញទំហឹងក្នុងការបង្កើតផែនការយុទ្ធសាស្ត្រដើម្បីផ្តល់សន្ទុះថ្មីដល់កំណើនហិរញ្ញវត្ថុ ប្រកបដោយភាពរឹងមាំ នៅក្នុងប្រតិបត្តិការអាជីវកម្ម។ ការផ្លាស់ប្តូរភាគទុនិក គឺជាឱកាសដែល ជោគជ័យ ហ្វាយនែន ទទួលបានការវិនិយោគបន្ថែមលើធនធានផ្សេងៗដើម្បីពង្រឹងសមត្ថភាពលើសកម្មភាពជាគោលមួយចំនួនរួមមានការគ្រប់គ្រងហិរញ្ញវត្ថុ សកម្មភាពប្រតិបត្តិការអាជីវកម្ម ការគ្រប់គ្រងហានិភ័យ និងសវនកម្មជាដើម។ លើសពីនេះការអភិវឌ្ឍលើផលិតផល បច្ចេកវិទ្យា ព័ត៌មានវិទ្យាទំនើប និងការគ្រប់គ្រងធនធានមនុស្ស ដែលជាកត្តាមិនអាចខ្វះបានសម្រាប់ ជោគជ័យ ហ្វាយនែន ក្នុងការប្រកួតប្រជែងក្នុងទីផ្សារហិរញ្ញវត្ថុកម្ពុជា។

ជោគជ័យ ហ្វាយនែន នឹងបន្តពង្រីកបណ្តាញសាខារបស់ខ្លួន ជាមួយនឹងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ជោគជ័យ មានការជឿជាក់យ៉ាងមុតមាំថាមាគ៌ាដឹកនាំប្រកបដោយសុភវិនិច្ឆ័យរបស់ភាគទុនិក នឹងនាំមកនូវភាពជោគជ័យសម្រាប់ស្ថាប័នទាំងមូល។

ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា អតិថិជន សាធារណជន និងអ្នកដែលពាក់ព័ន្ធទាំងអស់ដែលតែងតែផ្តល់ការគាំទ្រ និងការជឿជាក់មកលើ ជោគជ័យ ហ្វាយនែន។ ខ្ញុំបាទក៏សូមកោតសរសើរ ចំពោះគណៈគ្រប់គ្រង និងបុគ្គលិកគ្រប់ជាន់ថ្នាក់ សម្រាប់ការប្តេជ្ញាចិត្តបំពេញការងារ ជូនស្ថាប័នដើម្បីទទួលបានជោគជ័យក្នុងការអនុវត្តផែនការ និងសេវាបម្រើអតិថិជនប្រកបដោយភាពកក់ក្តៅក៏ដូចជារួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ប្រកបដោយស្ថេរភាព និងនិរន្តរភាព។



លោក MOON KYU CHOI
ប្រធានក្រុមប្រឹក្សាភិបាល



# សាររបស់អគ្គនាយក

ដើម្បីជាការលើកកម្ពស់មូលដ្ឋានការងារឲ្យកាន់តែល្អប្រសើរ ការអភិវឌ្ឍន៍ទៅលើគោលនយោបាយ ការធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានវិទ្យា និងការបង្កើតនូវវប្បធម៌ថ្មៃប្រឌិតខ្ពស់ បានក្លាយជាអាទិភាពចម្បងសម្រាប់គ្រឹះស្ថានចាប់តាំងពីធនាគារជាតិនៃកម្ពុជាបានផ្តល់ការអនុម័តទៅលើការធ្វើអនុប្បទានភាគហ៊ុន។

ខណៈគ្រឹះស្ថានរបស់យើងស្ថិតក្នុងស្ថានភាពនៃការចាប់ផ្តើម "វិសាលភាពអាជីវកម្មលុបលើវិស័យធនាគារ" គឺជាចក្ខុវិស័យក្នុងដំណាក់កាលដំបូងដើម្បីឈានទៅបង្កើនកិត្យានុភាពនៃកិត្តិនាម វប្បធម៌ចារឹក និងការស្វែងរកប្រាក់ចំណេញរបស់ជោគជ័យ។ ជោគជ័យបាននឹងកំពុងបោះជំហានទៅមុខប្រកបដោយភាពជឿជាក់ និងទំនុកចិត្តក្នុងចំណោមសាធារណជនប្រៀបដូចជាគ្រួសារតែមួយ។ ការប្តេជ្ញាចិត្ត និងភាពក្លៀវក្លារបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនតាមតួនាទី គឺជាសសរស្តម្ភនៃវឌ្ឍនភាពរបស់គ្រឹះស្ថាន។

ទោះបីស្ថិតក្នុងស្ថានភាពនៃការប្រឈមទៅនឹងបញ្ហាចម្បងៗពិសេស គឺការកំណត់ពិដានអត្រាការប្រាក់ដោយធនាគារជាតិនៃកម្ពុជាក្តី ជោគជ័យ នៅតែបន្តរីកលូតលាស់ទៅមុខ។ យើងបានព្យាយាមគ្រប់គ្រងបង្កើនផលប័ត្រឥណទានរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព ពោលគឺ ១.៣ លានដុល្លារ នៅខែធ្នូ ឆ្នាំ ២០១៦ រហូតដល់ ២.៥ លានដុល្លារ នៅដំណាច់ឆ្នាំ ២០១៧។ គិតត្រឹមដំណាច់ឆ្នាំ ២០១៧ ជោគជ័យ បានផ្តល់កម្ចីដល់អតិថិជនរបស់ខ្លួន ៣៥០ នាក់។ ទន្ទឹមនឹងនេះ បុគ្គលិកសរុបបានកើនឡើង ៣២០% ពោលគឺកើនពី ២៤ នៅឆ្នាំ ២០១៦ ដល់ ៧៧ នៅឆ្នាំ ២០១៧។ ទំហំទ្រព្យសកម្មកម្ចីត្រូវបានរំពឹងថា នឹងកើនដល់ជាង ១០ លានដុល្លារនៅដំណាច់ឆ្នាំ ២០១៨។

ដោយមានកំណើនប្រកបដោយស្ថេរភាព ជោគជ័យ គ្រោងនឹងពង្រីកតំបន់ប្រតិបត្តិការនៅខណ្ឌឫស្សីកែវ ក្រុងតាខ្មៅ និងខេត្តកំពង់ស្ពឺ សរុបទាំងអស់ចំនួន ៤ សាខាដើម្បីបំពេញតម្រូវការឥណទានរបស់អតិថិជនក៏ដូចជាផ្តល់នូវភាពងាយស្រួលដល់អតិថិជនដែលផ្តល់ទំនុកចិត្តមកលើ ជោគជ័យ ហ្វាយនែន។ យើងក៏នឹងត្រៀមបើកសាខាច្រើនបន្ថែមទៀតនៅតាមទីជនបទដែលនៅឆ្ងាយពីទីក្រុង ក្នុងឆ្នាំ ២០១៨ និង ២០១៩។

ក្នុងនាមគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ដែលខិតខំតស៊ូព្យាយាមគ្រប់ឧបសគ្គដើម្បីបុព្វហេតុការរីកចម្រើនរបស់គ្រឹះស្ថានតាំងពីការចាប់ផ្តើមរហូតមកដល់បច្ចុប្បន្ន។ លើសពីនេះ យើងក៏មានសេចក្តីអំណរយ៉ាងខ្លាំងចំពោះភាពស្មោះត្រង់ ការគាំទ្រ និងផ្តល់ភាពជឿជាក់ ក៏ដូចជាការសហការយ៉ាងល្អពីសំណាក់អតិថិជនទាំងអស់។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកប្រធានក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សាភិបាល និងភាគទុនិកទាំងអស់សម្រាប់ការចូលរួមផ្តល់មតិយោបល់ និងការគាំទ្រ។ ខ្ញុំសូមប្តេជ្ញាចិត្តក្នុងការដឹកនាំជោគជ័យឆ្ពោះទៅរកឧត្តមភាព និងភាពរីកចម្រើនដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យរបស់យើងគឺ **"វិសាលភាពអាជីវកម្មលុបលើវិស័យធនាគារ"**។



លោក CHEON GIL PARK
អគ្គនាយក

# ប្រវត្តិសង្ខេបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៥។ គ្រឹះស្ថានបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលទទួលបានអាជ្ញាប័ណ្ណចុះបញ្ជីលេខ ០០០០២៩៥២ ចេញនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ ដែលមានដើមទុនចុះបញ្ជីចំនួន ១លានដុល្លារអាមេរិក។ គ្រឹះស្ថានទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុទូទាំងប្រទេស ដោយមានអាជ្ញាប័ណ្ណលេខ MF-70 ថ្ងៃទី ២៧ ខែមេសាឆ្នាំ ២០១៦។

## សមិទ្ធិផលសម្រេចបានក្នុងឆ្នាំ ២០១៧

សមិទ្ធិផលសំខាន់ៗដែលជោគជ័យសម្រេចបានក្នុងឆ្នាំ ២០១៧ រួមមាន:

| | |
|---|---|
| **២១ សីហា ២០១៧** | លិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាស្តីពីការផ្ទេរភាគហ៊ុន ១០០% របស់ជោគជ័យ ទៅឲ្យក្រុមហ៊ុន Hanshin Engineering and Construction Co., Ltd. ចំនួន ៥១% និងក្រុមហ៊ុន Plus International Co., Ltd. ចំនួន ៤៩%។ |
| **១២ តុលា ២០១៧** | លិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាស្តីពីការទទួលស្គាល់ក្រុមប្រឹក្សាភិបាលថ្មីដែលលោក Moon Kyu Choi ជាប្រធានក្រុមប្រឹក្សាភិបាល លោក Jung Hoon kim ជាអភិបាលឯករាជ្យ និងលោក Cheon Gil Park ជាអភិបាល និងអគ្គនាយកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី។ |
| **២៦ កុម្ភៈ ២០១៨** | លិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាស្តីពីការបង្កើនដើមទុនរបស់គ្រឹះស្ថានពី ១ លានដុល្លារអាមេរិក ទៅ ១.៥ លានដុល្លារអាមេរិក។ |
| **១៤ មីនា ២០១៨** | លិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាស្តីពីការកែសម្រួលលក្ខន្តិកៈរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី។ |

## ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ ២០១៧

- កិច្ចប្រជុំថ្នាក់គ្រប់គ្រងរយៈពេល ២ថ្ងៃ គឺថ្ងៃទី២៨ និង២៩ ខែតុលា ឆ្នាំ២០១៧ ដែលបានរៀបចំឡើងនៅក្រុងកំពង់សោម ខេត្តព្រះសីហនុ។
- ពិធីជប់លៀងដំណាច់ឆ្នាំ២០១៧ ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ដែលមានការអញ្ជើញចូលរួមពីសំណាក់បុគ្គលិកគ្រប់ជាន់ថ្នាក់របស់គ្រឹះស្ថាន។

# រចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ជោគជ័យ ហ្វាយនែន ភីអិលស៊ី



# ភាគទុនិក

## ១. ក្រុមហ៊ុន HANSHIN ENGINEERING AND CONSTRUCTION CO., LTD.














## ២. ក្រុមហ៊ុន PLUS INTERNATIONAL CO., LTD.



សំណង់អគារលំនៅដ្ឋានដ៏ទំនើប និងសម្បូរបែប



សាលាវិជ្ជាជីវៈកែសម្ផស្ស នៅទីក្រុងហាណូយ ប្រទេសវៀតណាម

# ក្រុមប្រឹក្សាភិបាល



**លោក** MOON KYU CHOI | **ប្រធានក្រុមប្រឹក្សាភិបាល**

- បច្ចុប្បន្នជាប្រធាននាយកប្រតិបត្តិក្រុមហ៊ុន Hanshin Engineering and Construction Co., Ltd.
- បរិញ្ញាបត្រជាន់ខ្ពស់ពី Thunderbird School of Global Management, Arizona, USA.
- បរិញ្ញាបត្រពី Sogang University, Seoul, Korea.
- បុគ្គលិកក្រុមហ៊ុន Hyundai Merchant Marine
- បុគ្គលិកក្រុមហ៊ុន Hyundai Motor Company



**លោក** JUNG HOON KIM | **អភិបាលឯករាជ្យ**

- បច្ចុប្បន្នជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រុមហ៊ុន Hanshin Engineering and Construction Co., Ltd.
- បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពី Sogang University, Seoul, Korea.
- បុគ្គលិកក្រុមហ៊ុន Hyundai Marine & Fire Insurance



**លោក** CHEON GIL PARK | **អភិបាល**

- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី Yonsei University, Seoul, Korea.
- វិញ្ញាបនបត្រ UC Berkeley Marketing Diploma, California, USA.
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី Sogang University, Seoul, Korea.
- អគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Green Central Microfinance.
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card.
- ប្រធានក្រុមការងារក្រុមហ៊ុន Hyundai Card.
- ប្រធានក្រុមការងារក្រុមហ៊ុន CJ Hellovision

# គណៈគ្រប់គ្រង



### លោក CHEON GIL PARK | អគ្គនាយក

- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី Yonsei University, Seoul, Korea.
- វិញ្ញាបនបត្រ UC Berkeley Marketing Diploma, California, USA.
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី Sogang University, Seoul, Korea.
- អគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Green Central Microfinance.
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card.
- ប្រធានក្រុមការងារក្រុមហ៊ុន Hyundai Card.
- ប្រធានក្រុមការងារក្រុមហ៊ុន CJ Hellovision



### លោក យីវ ផាន់ណា | ប្រធាននាយក នាយកដ្ឋានឥណទាន

- បទពិសោធន៍ ១១ ឆ្នាំក្នុងវិស័យ មីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងសវនករផ្ទៃក្នុង ប្រធានក្រុមសវនករផ្ទៃក្នុង នាយកសាខា នាយកភូមិភាគ នាយករង នាយកដ្ឋានឥណទាន និងនាយកនាយកដ្ឋានឥណទានស្តីទីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសវនកម្ម និងបានចូលរួមសិក្ខាសាលាធំៗទាំងថ្នាក់ជាតិ និងអន្តរជាតិ រួមមានប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី។



### លោកស្រី ដេត សុជាតិ | ប្រធាននាយក នាយកដ្ឋានធនធានមនុស្ស និងទីផ្សារ

- បទពិសោធន៍ការងារ ១៧ ឆ្នាំក្នុងវិស័យ មីក្រូហិរញ្ញវត្ថុ និងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល
- ធ្លាប់ទទួលខុសត្រូវលើការគ្រប់គ្រងគម្រោង ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ និងការគ្រប់គ្រងរដ្ឋបាល
- នាយិការង នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាលនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ
- ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាទាំងក្នុងនិងក្រៅប្រទេស ដូចជា ថៃ ហ្វីលីពីន ឥណ្ឌា អ៊ីតាលី និងឥណ្ឌូនេស៊ី



### លោក ផេង ភ័ក្ត្រ | ប្រធាននាយក នាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល

- បទពិសោធន៍ការងារជាង ១១ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនអន្តរជាតិធំៗ
- ធ្លាប់កាន់តំណែង គណនេយ្យករ សវនករផ្ទៃក្នុង គណនេយ្យករ ជាន់ខ្ពស់ គណនេយ្យ គ្រប់គ្រងជាន់ខ្ពស់ ប្រធានផ្នែកវិភាគអាជីវកម្មប្រាក់សន្សំ និងប្រធានគ្រប់គ្រងហិរញ្ញវត្ថុ
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០១១



### លោក ចេង ប៊ុនធឿន | ប្រធាននាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន

- បទពិសោធន៍ការងារជាង ៩ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (អម្រឹត និងប្រ៊ីន សេនត្រល)
- ចាប់ផ្តើមការងារពីមន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យ អនុប្រធានផ្នែកកម្ចី ប្រធានផ្នែកគ្រប់គ្រងហានិភ័យ និងនាយករងប្រតិបត្តិ
- បរិញ្ញាបត្រផ្នែកអភិវឌ្ឍសេដ្ឋកិច្ចឆ្នាំ ២០០៧



### លោក ពៅ សំរេច | ប្រធាននាយក នាយកដ្ឋាននីតិកម្ម និងសវនកម្មផ្ទៃក្នុង

- បទពិសោធន៍ការងារជាង ១១ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ប្រាសាក់)
- ចាប់ផ្តើមការងារពីមន្ត្រីឥណទាន សវនករផ្ទៃក្នុង សវនករផ្ទៃក្នុងជាន់ខ្ពស់ និងប្រធានសវនករប្រចាំភូមិភាគ
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសវនកម្មឆ្នាំ ២០១៧



### លោក លី សូពិជា | នាយក នាយកដ្ឋានឥណទានសហគ្រាសខ្នាតតូច និងមធ្យម

- បទពិសោធន៍ការងារជាង ៩ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារឯកទេស
- ចាប់ផ្តើមការងារពីមន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ នាយកតំបន់ ប្រធានផ្នែកឥណទាន និងនាយករងសាខា
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារឆ្នាំ ២០១៤



### លោក ណែម ម៉ានៀន | នាយក នាយកដ្ឋានឥណទានទូទៅ

- បទពិសោធន៍ការងារជាង ៨ឆ្នាំ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់
- ចាប់ផ្តើមការងារពីមន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងឥណទានជាន់ខ្ពស់ នាយកសាខា ជំនួយការនាយក នាយកដ្ឋាន
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មឆ្នាំ ២០១៥



### លោក នី សុគារ | នាយក នាយកដ្ឋានអភិវឌ្ឍផលិតផល

- បទពិសោធន៍ការងារជាង ១០ឆ្នាំ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- នាយករងឥណទាន នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខមួយនៅក្នុងប្រទេសកម្ពុជា
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងឆ្នាំ ២០១១
- ចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាជាច្រើនពាក់ព័ន្ធ និងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ



### លោក ជួន សំណាង | នាយក នាយកដ្ឋានជ្រើសរើសបុគ្គលិក

- បទពិសោធន៍ការងារជាង ៥ឆ្នាំ នៅក្នុងផ្នែកធនធានមនុស្ស នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ និងធនាគារកាណាឌីយ៉ា
- មន្ត្រីសម្របសម្រួលអភិវឌ្ឍន៍កំណែទម្រង់នៅអង្គការមិនមែនរដ្ឋាភិបាល
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មឆ្នាំ ២០១៦



### លោកស្រី ម៉ៅ សុធារី | នាយិការ នាយកដ្ឋានហិរញ្ញវត្ថុ

- បទពិសោធន៍ការងារជាង ៧ឆ្នាំ នៅក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ
- មន្ត្រីគណនេយ្យជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ីរី ហ្វាយនែន
- មន្ត្រីគណនេយ្យករជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្រ្គីនសេនត្រល



### លោក ហុង កែវមន្នី | នាយក នាយកដ្ឋានព័ត៌មានវិទ្យា

- បទពិសោធន៍ការងារជាង ៦ឆ្នាំ នៅក្នុងផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា
- មន្ត្រីព័ត៌មានវិទ្យានៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្រ្គីនសេនត្រល
- ប្រធានផ្នែកព័ត៌មានវិទ្យានៅក្រុមហ៊ុន Ohana Home Japan



# ផលិតផលឥណទាន

## ១. កម្ចីទាន់ចិត្ត

### សេវាកម្មរហ័សទាន់ចិត្ត

- សេវាកម្មលឿនរហ័សក្នុងការផ្តល់កម្ចី
- ចូលរួមក្នុងការលើកស្ទួយជីវភាពដូចជា ពង្រីកអាជីវកម្មខ្នាតតូច ទិញម៉ូតូ កែលម្អគេហដ្ឋាន បង់ថ្លៃសិក្សា រួមនឹងគោលបំណងផ្សេងៗទៀត។

### លក្ខណៈពិសេស

- រូបិយប័ណ្ណ : ខ្មែររៀល និងដុល្លារអាមេរិក
- រយៈពេល : រហូតដល់ ៣៦ ខែ
- ទំហំកម្ចី : រហូតដល់ ៣,០០០ ដុល្លារ
- អត្រាការប្រាក់ : សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

## ២. កម្ចីប្រាក់បៀវត្ស

### សម្រាប់អ្នកធ្វើការដែលមានប្រាក់ចំណូលខ្ពស់

ដើម្បីជាការឆ្លើយតបកំណើននៃវិស័យហិរញ្ញវត្ថុ ក៏ដូចជាតម្រូវការនៃសេវាកម្មមីក្រូហិរញ្ញវត្ថុ នាយកដ្ឋានឥណទានមានគ្រោងនឹងបង្កើតឲ្យមាននូវកម្ចីប្រាក់បៀវត្ស។ ផលិតផលនេះមានគោលដៅចម្បងសម្រាប់រោចក្រកាត់ដេរ បុគ្គលិកក្រុមហ៊ុនឯកជន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល បុគ្គលិករដ្ឋាភិបាល កម្មករសំណង់ និងបុគ្គលិករបស់ ជោគជ័យ ដែលចំណូលគ្រួសារទទួលបានមកពីប្រាក់បៀវត្ស។ ផលិតផលនេះនឹងបញ្ច្រៀបចូលដើម្បីចាប់យកចំណែកទីផ្សារថ្មី។

### លក្ខណៈពិសេស
- រូបិយប័ណ្ណ : ខ្មែររៀល និងដុល្លារអាមេរិក
- រយៈពេល : រហូតដល់ ៧២ ខែ
- ទំហំកម្ចី : រហូតដល់ ១,០០០ ដុល្លារ
- អត្រាការប្រាក់ : សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

## ៣. កម្ចីផ្ទាល់ខ្លួន

### កម្ចីប្រើប្រាស់ក្នុងគោលបំណងផ្ទាល់ខ្លួន
- អតិថិជនដែលចង់ទិញសម្ភារៈប្រើប្រាស់ផ្សេងៗផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ
- សម្ភារៈប្រើប្រាស់សំដៅទៅលើសម្ភារៈផ្សេងៗទាំងថ្មី ឬមួយទឹក ដែលមានអាយុកាលមិនលើសពី៥ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទផលិត

### លក្ខណៈពិសេស
- រូបិយប័ណ្ណ : ខ្មែររៀល និងដុល្លារអាមេរិក
- រយៈពេល : រហូតដល់ ៧២ ខែ
- ទំហំកម្ចី : រហូតដល់ ១០០,០០០ ដុល្លារ
- អត្រាការប្រាក់ : សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

### កម្ចីកែលម្អគេហដ្ឋាន
- អតិថិជនដែលមានបំណងកែលម្អ ឬបង្ហើយការសាងសង់គេហដ្ឋានរបស់ខ្លួន
- អតិថិជនអាចខ្ចីរហូតដល់ ១០០,០០០ ដុល្លារ (ឬស្មើនឹងទំហំនេះសម្រាប់រូបិយប័ណ្ណផ្សេង) ជាមួយនឹងអត្រាការប្រាក់ដ៏សមរម្យដោយផ្អែកលើទំហំកម្ចី និងរយៈពេលខ្ចី

### លក្ខណៈពិសេស
- រូបិយប័ណ្ណ : ខ្មែររៀល និងដុល្លារអាមេរិក
- រយៈពេល : រហូតដល់ ៧២ ខែ
- ទំហំកម្ចី : រហូតដល់ ១០០,០០០ ដុល្លារ
- អត្រាការប្រាក់: សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

## ៤. កម្ចីអាជីវកម្ម ខ្នាតតូច និងមធ្យម

### ១.កម្ចីអាជីវកម្ម
ផលិតផលនេះជាកម្ចីដែលមានលក្ខណៈល្អបំផុតសម្រាប់អតិថិជនដែលមានបំណងបើកអាជីវកម្មផ្ទាល់ខ្លួន។ ផលិតផលនេះត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលបើកអាជីវកម្មខ្នាតតូច និងបង្កើនដើមទុនដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។ ផលិតផលនេះក៏សម្រាប់ការចាប់ផ្តើមអាជីវកម្មថ្មីផងដែរ។

### លក្ខណៈពិសេស
- រូបិយប័ណ្ណ : ខ្មែររៀល ដុល្លារអាមេរិក និងថៃបាត
- រយៈពេល : រហូតដល់ ៧២ ខែ
- ទំហំកម្ចី: រហូតដល់ ១០០,០០០ ដុល្លារ
- អត្រាការប្រាក់ : សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

### ២. កម្ចីសហគ្រាសខ្នាតតូច និងមធ្យម

បើសិនលោកអ្នកមានបំណងក្នុងការបើកអាជីវកម្ម ឬពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួន ជោគជ័យ នឹងផ្តល់ជូនកម្ចីខ្នាតតូច និងមធ្យម សម្រាប់ជាដើមទុនក្នុងការចាប់ផ្តើម និងដំណើរការអាជីវកម្មរបស់លោកអ្នក ដែលរួមមានការទិញលក់ អាជីវកម្ម និងសេវាកម្មផ្សេងៗ ដែលហៅថា កម្ចីសហគ្រាស ខ្នាតតូច និងមធ្យម។

#### លក្ខណៈពិសេស

- រូបិយប័ណ្ណ : ខ្មែររៀល ដុល្លារអាមេរិក និងថៃបាត
- រយៈពេល : រហូតដល់ ៨៤ ខែ
- ទំហំកម្ចី : រហូតដល់ ១០០,០០០ ដុល្លារ
- អត្រាការប្រាក់ : សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

## ៥. កម្ចីកសិកម្ម

### សម្រាប់កសិករ

សម្រាប់កសិករដែលមានបំណងពង្រីកសកម្មភាពកសិកម្មរបស់ខ្លួន ពួកគេអាចស្នើសុំកម្ចីកសិកម្មរបស់ ជោគជ័យ ហ្វាយនែន ផងដែរ។ កម្ចីប្រភេទនេះត្រូវបានបង្កើតឡើងដែលមានលក្ខណៈពហុបំណង គឺសម្រាប់កសិកម្មខ្នាតតូច ការដាំដំណាំផ្សេងៗ និងការចិញ្ចឹមសត្វ ជាដើម។

#### លក្ខណៈពិសេស

- រូបិយប័ណ្ណ : ខ្មែររៀល និងដុល្លារអាមេរិក
- រយៈពេល : រហូតដល់ ៤៨ ខែ
- ទំហំកម្ចី : រហូតដល់ ១០,០០០ ដុល្លារ
- អត្រាការប្រាក់ : សមរម្យ
- វិធីសាស្ត្រក្នុងការបង់សង : អាចជ្រើសរើសបាន

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្តីសោមនស្សរីករាយធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ហិរញ្ញវត្ថុរបស់ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា (“គ្រឹះស្ថាន”) ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់គ្រឹះស្ថាន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដែលមាននិរន្តរភាពជូនសហគ្រាសធុនតូច និងមធ្យម និងគ្រួសារ ដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់គ្រឹះស្ថាន សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ មានដូចខាងក្រោម:

| | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម 31 ធ្នូ ឆ្នាំ 2017 | | ការិយបរិច្ឆេទចាប់ពី ថ្ងៃទី 2 ខែ មីនា ឆ្នាំ 2016 (កាលបរិច្ឆេទបង្កើតគ្រឹះស្ថាន) ដល់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់ខាតមុនបង់ពន្ធ | (259,943) | (1,049,390) | (15,053) |
| ពន្ធលើប្រាក់ចំណេញ | (3,253) | (13,132) | (1,457) |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **(263,196)** | **(1,062,522)** | **(16,510)** |

## ភាគលាភ

គ្រឹះស្ថានពុំបានប្រកាស ឬបង់ភាគលាភ និងក្រុមប្រឹក្សាភិបាលមិនបានផ្តល់អនុសាសន៍ ក្នុងការបែងចែកភាគលាភ ដែលត្រូវបង់ក្នុងការិយបរិច្ឆេទនេះទេ ។

## ដើមទុន

នៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2017 ភាគទុនិកបច្ចុប្បន្ន បានចុះកិច្ចព្រមព្រៀងទិញ និងលក់ជាមួយគ្រឹះស្ថាន Hanshin Engineering and Construction Co., Ltd និង Plus International Co., Ltd ដើម្បីលក់ភាគហ៊ុនចំនួន 100% របស់ខ្លួន។ គ្រឹះស្ថានបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា អំពីការផ្ទេរភាគហ៊ុន នៅថ្ងៃទី21 ខែសីហា 2017។

នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 គ្រឹះស្ថានមានដើមទុនសរុប 1,500,000 ដុល្លារអាមេរិក ស្មើរនឹង 6,000,000,000 រៀល។ គ្រឹះស្ថានបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា អំពីការដំឡើងដើមទុននៅថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2018។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធន លើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថា មិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់ សម្រាប់ឥណទាន ដែលជាប់សង្ស័យ ។

សំរាប់ការិយបរិច្ឆេទបញ្ចប់ត្រឹម ថ្ងៃទី31 ខែ ធ្នូ ឆ្នាំ2017 គ្រឹះស្ថានបានលុបឥណទានចេញពីបញ្ជីដែលស្មើរនឹងទឹកប្រាក់ 7,882 ដុល្លារអាមេរិក។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់គ្រឹះស្ថាន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថា នឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានថា មានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលនឹង ធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់គ្រឹះស្ថាន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ក្រៅអំពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះគ្រឹះស្ថាន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់គ្រឹះស្ថាន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់គ្រឹះស្ថាន ដែលត្រូវសង ឬ អាចនឹងត្រូវសងក្នុងរយៈពេល 12 ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹង ប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់គ្រឹះស្ថាន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅ ពេលដែលដល់ថ្ងៃកំណត់។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរៀបរាប់នៅក្នុង របាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាល មានមតិថាលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់គ្រឹះស្ថាន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍ នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់គ្រឹះស្ថានក្នុងការិយបរិច្ឆេទ ដែល របាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

នៅថ្ងៃទី 13 ខែ មីនា ឆ្នាំ 2017 ធនាគារជាតិនៃកម្ពុជាបានចេញនូវប្រកាសលេខ ធ7-017-109 ប្រ.ក ស្តីពីការកំណត់ ពិដានអត្រាការប្រាក់ឥណទាន ដោយតម្រូវឲ្យគ្រឹះស្ថានត្រូវកំណត់អត្រាការប្រាក់ឥណទានមិនឲ្យលើសពី 18% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។ ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំងឥណទានរៀបចំឡើងវិញ និងបុនហិរញ្ញប្បទាន ដោយមានចុះហត្ថលេខា និង/ឬស្នាមផ្តិតមេដៃចាប់ពីថ្ងៃទី 1 ខែ មេសា ឆ្នាំ 2017 ។

ពុំមានព្រឹត្តិការណ៍សារវន្តផ្សេងទៀតកើតឡើងក្រោយនាថ្ងៃចេញរបាយការណ៍នេះ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សំគាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមានៈ

- **Mr. Moon Kyu Choi** ប្រធានក្រុមប្រឹក្សាភិបាល
- **Mr. Cheon Gil Park** អភិបាល និងអគ្គនាយកប្រតិបត្តិ
- **Mr. Jung Hoon Kim** អភិបាលឯករាជ្យ

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុង គោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ឬលិខិតបំណុលពីគ្រឹះស្ថាន ឬពីក្រុមហ៊ុនដទៃទៀតទេ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួល បាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយគ្រឹះស្ថាន ឬដោយក្រុមហ៊ុនពាក់ព័ន្ធ និងក្រុមហ៊ុនដែលសមាជិក ក្រុមប្រឹក្សាភិបាល នោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវដើម្បីចង្អុលបង្ហាញនូវ ភាពត្រឹមត្រូវនៃ ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថាន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ :

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ខ) អនុវត្តទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និង ការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញពន្យល់ និងកំណត់ បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្មនិងប្រើប្រាស់ មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការគ្រឹះស្ថាន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំគ្រឹះស្ថានឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់គ្រឹះស្ថានហើយត្រូវប្រាកដថាកិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

# ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលជាមតិរបស់យើងខ្ញុំ បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ជោគជ័យ ហ្វាយនែន ភីអិលស៊ី** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរទឹកប្រាក់ របស់គ្រឹះស្ថាន សម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលៈ




**Mr. Cheon Gil Park**
អគ្គនាយកប្រតិបត្តិ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 13 ខែមេសា ឆ្នាំ 2018

# របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះភាគទុនិក ជោគជ័យ ហ្វាយនែន ភីអិលស៊ី**

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ជោគជ័យ ហ្វាយនែន ភីអិលស៊ី** ហៅកាត់ថា ("គ្រឹះស្ថាន") ដែលរួមមាន តារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 និងរបាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 និងកំណត់សំគាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗផងដែរ។

ជាមតិរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់គ្រឹះស្ថាននាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2017 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់គ្រឹះស្ថាន សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាម ស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីធនាគារដោយស្របទៅតាមតម្រូវការ ក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញ នូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានសម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ត្រូវបាន ធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបញ្ជាក់មតិភាពត្រឹមត្រូវលើរបាយការណ៍នៅថ្ងៃទី 28 ខែមេសា ឆ្នាំ2017។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់ នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត។

ប្រសិនបើ ការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំ សន្និដ្ឋាន ថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វី ដែលត្រូវរាយការណ៍ ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រង មានភារៈ ទទួលខុសត្រូវ លើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោម ទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់ បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធ ត្រួតពិនិត្យផ្ទៃក្នុងដែល អ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការ បង្ហាញ ខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ គ្រឹះស្ថានក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន (ប្រសិនបើពាក់ព័ន្ធ) នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការគ្រឹះស្ថាន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់គ្រឹះស្ថាន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។

អំណះអំណាង សមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេល នៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស ជាសារវន្ត អាចកើតឡើង ដោយសារការក្លែងបន្លំ ឬកំហុសឆ្គងហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គង តែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោង លើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការ វិនិច្ឆ័យដែលប្រកបទៅ ដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារ តែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូល នូវភស្តុតាងដែលមាន លក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យ ដែលមិន អាចរកឃើញនូវការបង្ហាញខុសជា សារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការ បង្ហាញខុស កើតឡើងពីកំហុស ឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បី រៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាព នៃការគ្រប់គ្រងផ្ទៃក្នុង របស់គ្រឹះស្ថានឡើយ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលគ្រឹះស្ថាន បានប្រើប្រាស់ និងភាពសម ហេតុផលនៃការប៉ាន់ ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើង ដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ របស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅ លើភស្តុតាងសវនកម្ម ដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្ត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែល អាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់គ្រឹះស្ថាន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋាន ថាមានអត្ថិភាព នៃភាព

មិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការ លាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែល ប្រមូលបានត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យគ្រឹះស្ថានបញ្ឈប់និរន្តរភាពអាជីវកម្ម ។

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការ លាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេច បាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

- យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំង ចំណុចខ្វះខាត នៃការគ្រប់គ្រងផ្ទៃ ក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **អេចអឌីភី & អឹសូស៊ីអេត ខូ អិលធីឌី**




**ពៅ ដារ៉ា**

**Partner**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 13 ខែមេសា ឆ្នាំ 2018

# ជោគជ័យ ហ្វាយនែន ភីអិលស៊ី
## តារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

| | នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 | | នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ | 2,520 | 10,173 | 1,418 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | 552,256 | 2,229,457 | 52,031 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 413,302 | 1,668,500 | 4,609 |
| ឥណទានផ្តល់ដល់អតិថិជន | 2,467,753 | 9,962,319 | 1,368,660 |
| ទ្រព្យសកម្មផ្សេងៗ | 50,689 | 204,631 | 23,520 |
| ទ្រព្យ និងបរិក្ខារ | 135,949 | 548,826 | 92,369 |
| ទ្រព្យសកម្មអរូបី | 19,551 | 78,927 | 21,594 |
| **សរុបទ្រព្យសកម្ម** | **3,642,020** | **14,702,833** | **1,564,201** |
| **បំណុល និងមូលធន** | | | |
| **បំណុល** | | | |
| បំណុលផ្សេងៗ | 33,283 | 134,362 | 3,977 |
| បំណុលពន្ធលើប្រាក់ចំណេញ | - | - | 251 |
| បុរេប្រទានពីភាគទុនិក | 1,700,000 | 6,862,900 | 576,483 |
| បំណុលរយៈពេលយូរ | 688,443 | 2,779,244 | - |
| **សរុបបំណុល** | **2,421,726** | **9,776,506** | **580,711** |
| **មូលធន** | | | |
| ដើមទុន | 1,000,000 | 4,037,000 | 1,000,000 |
| ដើមទុនបន្ថែមក្នុងឆ្នាំ | 500,000 | 2,018,500 | - |
| ប្រាក់ខាតបង្គរ | (16,510) | (66,651) | - |
| ខាតក្នុងឆ្នាំ | (263,196) | (1,062,522) | (16,510) |
| **សរុបមូលធន** | **1,220,294** | **4,926,327** | **983,490** |
| | | | |
| **សរុបបំណុល និងមូលធន** | **3,642,020** | **14,702,833** | **1,564,201** |

# ជោគជ័យ ហ្វាយនែន ភីអិលស៊ី
## របាយការណ៍លទ្ធផលសម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

| | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 | | ការិយបរិច្ឆេទចាប់ពី ថ្ងៃទី 2 ខែ មីនា ឆ្នាំ 2016 (កាលបរិច្ឆេទបង្កើតគ្រឹះស្ថាន) ដល់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ចំណូលពីការប្រាក់** | 269,070 | 1,086,236 | 130,092 |
| ចំណាយការប្រាក់ | (91,669) | (370,068) | (18,034) |
| **ចំណូលពីការប្រាក់សុទ្ធ** | **177,401** | **716,168** | **112,058** |
| ចំណូលពីប្រតិបត្តិការ ផ្សេងៗ | 56,385 | 227,626 | 28,465 |
| ចំណាយទូទៅ និងរដ្ឋបាល | (443,320) | (1,789,683) | (147,907) |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | (50,409) | (203,501) | (7,669) |
| ប្រាក់ខាតមុនដកពន្ធ | (259,943) | (1,049,390) | (15,053) |
| ចំណាយពន្ធលើប្រាក់ចំណេញ | (3,253) | (13,132) | (1,457) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **(263,196)** | **(1,062,522)** | **(16,510)** |

# ជោគជ័យ ហ្វាយនែន ភីអិលស៊ី
## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

| | ដើមទុន ដុល្លារអាមេរិក | ប្រាក់ខាតបង្គរដុល្លារអាមេរិក | សរុបដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនាថ្ងៃទី2 ខែ មីនា ឆ្នាំ 2016 (កាលបរិច្ឆេទបង្កើតគ្រឹះស្ថាន) | - | - | - |
| ការបង្កើតដើមទុន | 1,000,000 | - | 1,000,000 |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | (16,510) | (16,510) |
| **សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016** | **1,000,000** | **(16,510)** | **983,490** |
| សមតុល្យនាថ្ងៃទី 01 ខែមករា ឆ្នាំ2017 | 1,000,000 | (16,510) | 983,490 |
| ដើមទុនបន្ថែមសម្រាប់ការិយបរិច្ឆេទ | 500,000 | - | 500,000 |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | (263,196) | (263,196) |
| **សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017** | **1,500,000** | **(279,706)** | **1,220,294** |
| **(សមមូលពាន់រៀល)** | **6,055,500** | **(1,129,173)** | **4,926,327** |

# ជោគជ័យ ហ្វាយនែន ភីអិលស៊ី
## របាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017

| | សម្រាប់ការិយបរិច្ឆេទ បញ្ចប់ត្រឹម ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2017 | | ការិយបរិច្ឆេទចាប់ពី ថ្ងៃទី 2 ខែ មីនា ឆ្នាំ 2016 (កាលបរិច្ឆេទបង្កើតគ្រឹះស្ថាន) ដល់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **លំហូរទឹកប្រាក់ពី សកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់សុទ្ធប្រើក្នុង សកម្មភាពប្រតិបត្តិការ | (1,340,721) | (5,412,491) | (1,395,266) |
| **លំហូរទឹកប្រាក់ពី សកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (61,219) | (247,141) | (100,098) |
| ការទិញទ្រព្យសកម្មអរូបី | - | - | (23,061) |
| ប្រាក់តម្កល់ធានាលើដើមទុន | - | - | (50,000) |
| **លំហូរទឹកប្រាក់ពី សកម្មភាពហិរញ្ញប្បទាន** | | | |
| បុរេប្រទានពីភាគទុនិក | 1,123,517 | 4,535,638 | 576,483 |
| បំណុលរយៈពេលយូរ | 688,443 | 2,779,244 | - |
| សាច់ប្រាក់ទទួលបានពី ដើមទុនថ្មី | - | - | 1,000,000 |
| ដើមទុនបន្ថែមក្នុងឆ្នាំ | 500,000 | 2,018,500 | - |
| សាច់ប្រាក់សុទ្ធទទួលបាន ពីសកម្មភាពហិរញ្ញប្បទាន | 2,311,960 | 9,333,382 | 1,576,483 |
| ការកើនឡើងនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | 910,020 | 3,673,750 | 8,058 |
| សាច់ប្រាក់ និងសាច់ប្រាក់ សមមូលនាដើមការិយបរិច្ឆេទ | 8,058 | 32,530 | - |
| **សាច់ប្រាក់ និងសាច់ប្រាក់ សមមូលនាដើមការិយបរិច្ឆេទ** | **918,078** | **3,706,280** | **8,058** |

ការិយាល័យកណ្ដាល
ផ្ទះលេខ ៩-១១ ផ្លូវវេងស្រេង សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ +៨៥៥-២៣ ៩២២ ១២៦ | អ៊ីម៉ែល៖ info@chokchey.net | គេហទំព័រ៖ www.chokchey.net